# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 621

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងបង្កើតមូលដ្ឋានស្រាវជ្រាវព្រៃឈើ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | 01/01/24 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/26 |

៣. ចំណាយគម្រោងសរុប $3,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | Forestry Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលព្រៃឈើ |

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

ស្នូលរបស់យុទ្ធសាស្ត្របញ្ចកោណ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

-មូលដ្ឋានសិក្សាស្រាវជ្រាវ និងថ្នាលបណ្ដុះកូនឈើ ត្រូវបានកំណត់ និងសាងសង់

-សមត្ថភាពរបស់មន្ត្រីរដ្ឋបាលព្រៃឈើផ្នែកសិក្សាស្រាវជ្រាវត្រូវបានបង្កើន

-រៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានស្រាវជ្រាវការស្ដារព្រៃឈើឡើងវិញ និងសកម្មភាពស្រាវជ្រាវ

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស Forestry Sector

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កោះកុង, កំពង់ធំ, សៀមរាប, មណ្ឌលគីរី,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងរួមរបស់គម្រោង គឺបង្កើតមូលដ្ឋានស្រាវជ្រាវដែលនឹងធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពក្នុងការស្តារព្រៃឈើឡើងវិញ និងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តភាពនៅក្នុងប្រទេសកម្ពុជា។ គោលបំណងជាក់លាក់ គឺ

-បង្កើតស្ថានីយស្រាវជ្រាវព្រៃឈើនៅក្នុងខេត្តកោះកុង កំពង់ធំ និងមណ្ឌលគីរី ដែលនឹងធ្វើជាទីតាំងសិក្សាស្រាវជ្រាវអំពីការងារស្តារព្រៃឈើ និងការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព។

-កសាងសមត្ថភាព/បណ្តុះបណ្តាលមន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃក្នុងការអនុវត្តការងារស្រាវជ្រាវ និងគំហើញបច្ចេកទេសថ្មីៗ។

- អនុវត្តការងារស្រាវជ្រាវនៅតាមស្ថានីយស្រាវជ្រាវទាំង០៣ទីតាំង និងស្ថានីយស្រាវជ្រាវដែលមាន ស្រាប់នៅខេត្តសៀមរាប។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងបង្កើតមូលដ្ឋានស្រាវជ្រាវព្រៃឈើត្រូវបានអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ។ សមាសធាតុសំខាន់របស់គម្រោង រួមមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធ/ស្ថានីយស្រាវជ្រាវ និងថ្នាលបណ្តុះកូនឈើ នៅក្នុងខេត្តកោះកុង កំពង់ធំ និងមណ្ឌលគីរី បណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃក្នុងការអនុវត្តការងារស្រាវជ្រាវនៅតាមស្ថានីយនិមួយៗ និងគំហើញបច្ចេកទេសថ្មីៗ និងការផ្ទេរចំណេះដឹងដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងការចងក្រងបោះពុម្ពចែករំលែក នូវលទ្ធផលនៃការការងារស្រាវជ្រាវ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងនេះ នឹងប្រើប្រាស់នូវបច្ចេកទេសសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពនៅតាមស្ថានីយនិមួយៗ ដែលវានឹងក្លាយជាទីតាំងសិក្សាស្រាវជ្រាវនៅតាមខេត្តនិមួយៗ។ គម្រោងនេះ នឹងជួយពង្រឹងសមត្ថភាពរបស់មន្ត្រីរដ្ឋបាល ព្រៃឈើ ទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ធ្វើការស្រាវជ្រាវដោយមានការចូលរួមជាមួយនឹងអ្នក ពាក់ពន្ធ័នានា និងពង្រីក ផ្សព្វផ្សាយនូវចំណេះដឹង និងបទពិសោធន៍នៃការអនុវត្តនៅតាមស្ថានីយនិមួយៗ ប្រៀបដូចជា កន្លែងសម្រាប់សិក្សាសម្រាប់សិក្ខាកាមនិមួយៗ។ ដើម្បីធានានូវនិរន្តភាពនៃមូលដ្ឋានស្រាវជ្រាវនិមួយៗ និងដើម្បីលើកទឹកចិត្តឲ្យមានការចូលរួមកាន់តែល្អប្រសើរ សកម្មភាពជាចំបងមួយក្នុង  ចំណោមសកម្មភាពនានា គឺការរៀបចំផែនការគ្រប់គ្រង ព្រៃសហគមន៍។ វាមានន័យថា សហគមន៍ព្រៃឈើ ត្រូវអនុលោមតាម ដំណើការនិយត័កម្មសហគមន៍ព្រៃឈើ និងជំហ៊ាន ទាំង០៨ នៃដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ (ដូចជាការធ្វើ សារពើ ភណ្ឌ និងការសរសេរផែនការគ្រប់គ្រង)។ បទពិសោធន៍នៃការសិក្សាស្រាវជ្រាវ នឹងត្រូវបានចងក្រង និងបោះពុម្ពចែករំលែកបង្កើន ចំណេះដឹង (ការងារស្តារព្រៃឈើ និងការប្រើប្រាស់ធនធានធម្មជាតិ) ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងការងារស្តារព្រៃឈើឡើងវិញ គម្រោងនឹងសាកល្បងប្រើប្រាស់បច្ចេកទេសដាំស្តារព្រៃឈើឡើងវិញដោយចំណាយតិច (ការដាំដោយគ្រាប់។ល។) ការដាក់ជី ការធ្វើតេស្តសាកល្បងការងារដាំកូនឈើដុះលូតលាស់លឿន ការគ្រប់គ្រង និងប្រើប្រាស់នូវធនធានអនុផលព្រៃឈើ (ផ្តៅ ឬស្សី ធនធានធម្មជាតិ និងអនុផលផ្សេងៗទៀតជាច្រើន។ នៅក្នុងករណីខ្លះ នៅពេលដែលសហគមន៍បានបំពេញទៅតាមតម្រូវការរបស់ក្រុមប្រជាសហគមន៍ដោយបញ្ចប់នូវដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍។ ផ្នែកមួយនៃការស្រាវជ្រាវ គឺផ្តោតការយកចិត្តទុក្ខដាក់ទៅការប្រើប្រាស់ប្រកបដោយនិរន្តភាព និងការបន្ថែមតម្លៃទៅលើធនធានព្រៃឈើ (ដូចជាផ្សិត ផ្សង ឬស្សី ផ្តៅ និងផលិតផលព្រៃឈើផ្សេងទោត។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងបង្កើតមូលដ្ឋានស្រាវជ្រាវព្រៃឈើ នឹងរួមចំណែកយ៉ាងច្រើនសម្រាប់វិស័យព្រៃឈើ ជាពិសេសគឺ រដ្ឋបាលព្រៃឈើ សហគមន៍ព្រៃឈើ សហគមន៍មូលដ្ឋាន សហគ្រាសអនុផលព្រៃឈើ និងអ្នកដែលពាក់ព័ន្ធនានាក្នុងវិស័យព្រៃឈើ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ មិនមានផលប៉ះពាល់ទៅដល់ប្រជាជន និងបរិស្ថានជុំវិញនោះទេ។ គម្រោងនឹងជួយដល់ការការពារ និងស្តារឡើងវិញនូវធនធានព្រៃឈើ ក៏ដូចជាកាត់បន្ថយភាពក្រីក្រសហគមន៍មូលដ្ឋាន ហើយប្រជាសហគមន៍មួយចំនួន នឹងទទួលបានប្រភពចំនួលបន្ថែមពីការ ប្រមូលផល-អនុផលព្រៃឈើ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីទេ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មន្ត្រីទទួលអនុវត្តន៍គម្រោងមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**-បង្កើតស្ថានីយស្រាវជ្រាវព្រៃឈើនៅក្នុងខេត្តកោះកុង កំពង់ធំ និងមណ្ឌលគិរី ដែលនឹងធ្វើជាទីតាំងសិក្សាស្រាវជ្រាវអំពីការងារស្តារព្រៃឈើ និងការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព។**

**-កសាងសមត្ថភាព/បណ្តុះបណ្តាលមន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃក្នុងការអនុវត្តការងារស្រាវជ្រាវ និងគំហើញបច្ចេកទេសថ្មីៗ។**

**-អនុវត្តការងារស្រាវជ្រាវនៅតាមស្ថានីយស្រាវជ្រាវទាំង០៣ទីតាំង និងស្ថានីយស្រាវជ្រាវដែលមាន ស្រាប់នៅខេត្តសៀមរាប។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**គម្រោងនេះស្ថិតក្រោមជំនួយប្រទេសចិន និងមានរយៈពេលអនុវត្ត ៣ឆ្នាំ ២០២០ ដល់ឆ្នាំ ២០២២។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្នើ | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 1,125.0 | 963.0 | 912.0 | 3,000.0 | 3,000.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 75.0 | 75.0 | 75.0 | 225.0 | 225.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 1,000.0 | 838.0 | 837.0 | 2,675.0 | 2,675.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 50.0 | 50.0 | 0.0 | 100.0 | 100.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,125.0 | 963.0 | 912.0 | 3,000.0 | 3,000.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Donor Sought | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 1,125.0 | 963.0 | 912.0 | 3,000.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: